ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង អប់រំ យុវជន និង កីឡា
លេខ : ២៤១៩..........អយក.ក.ប

# លិខិតថ្លែងអំណរគុណ

ជូន លោក ម៉ាធិនជីត ស៊ិង្ហ
នាយកវិទ្យាស្ថាន អិល_ស៊ីទីអាយ

*លោកនាយក ជាទីស្រឡាញ់រាប់អាន*

ខ្ញុំមានក្ដីសោមនស្សរីករាយសូមសំដែងនូវការសរសើរដ៏ជ្រាលជ្រៅ ដល់លោកនាយក ព្រមទាំងសហការី_សហការិនី នៃវិទ្យាស្ថាន អិល_ស៊ីទីអាយ ចំពោះកិច្ចខំប្រឹងប្រែងបង្កើតនូវកម្មវិធីបណ្ដុះបណ្ដាលសំរាប់យុវជន_យុវនារីក្រីក្រដែលបានបោះបង់ការសិក្សា នៅតាមបណ្ដាខេត្តនានា ក្នុងព្រះរាជាណាចក្រកម្ពុជា ។ ក្រសួងអប់រំ យុវជន និងកីឡាសូមសរសើរ និងគាំទ្រផងដែរចំពោះ កិច្ចខំប្រឹងប្រែងបង្កើតឡើងនូវមជ្ឈមណ្ឌលបណ្ដុះបណ្ដាល និងអភិវឌ្ឍភាពជាអ្នកដឹកនាំ និង អាកប្បកិរិយា តាមបណ្ដាខេត្តនានារបស់វិទ្យាស្ថាន បើទុកជាត្រូវប្រឈមមុខនឹងកង្វះខាតផ្នែកហិរញ្ញវត្ថុ ។

ខ្ញុំសូមអំពាវនាវដល់ស្ថាប័ន គ្រឹះស្ថានអប់រំបណ្ដុះបណ្ដាល និងបណ្ដាអង្គការនានា ទាំងក្នុង និងក្រៅប្រទេសសូមជួយផ្ដល់នូវការជួយឧបត្ថម្ភ និងកិច្ចសហការដល់វិទ្យាស្ថាន អិល_ស៊ីទីអាយ ជាសំភារៈ និងថវិកាដើម្បីវិទ្យាស្ថានមានលទ្ធភាពគ្រប់គ្រាន់បន្តចូលរួមចំណែកបណ្ដុះបណ្ដាលធនធានមនុស្ស បំពេញតាមតំរូវការចាំបាច់នៅកម្ពុជា ជាពិសេសសំរាប់ជនក្រីក្រកម្ពុជានៅតាមបណ្ដាខេត្តនានាទូទាំងប្រទេស។

ខ្ញុំសូមថ្លែងអំណរគុណ និងសូមសរសើរជាថ្មីម្ដងទៀតដល់វិទ្យាស្ថាន អិល_ស៊ីទីអាយ ចំពោះការធ្វើពលិកម្មដ៏ធំធេងនេះ និងសូមជូនពរសុភមង្គល និងជ័យជំនះគ្រប់ប្រការ !

សូមលោកនាយកទទួលនូវសេចក្ដីស្រឡាញ់រាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

... ខែ សីហា ឆ្នាំ ២០០១
រដ្ឋមន្ត្រី

តុល.ឡះ

អាស័យដ្ឋានលេខ៨០ មហាវិថីព្រះនរោត្ដម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៧ ២៥៣ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
Email: crsmeys@camnet.com.kh Web Site: www.moeys.gov.kh